ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន និងឯកសារ

# សេចក្ដីជូនព័ត៌មាន

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលការបំភ្លឺផ្លូវការពីស្ថានទូតឥណ្ឌូនេស៊ី នៅភ្នំពេញពាក់ព័ន្ធនឹងអត្ថបទដែលមានចំណងជើង "**ក្រោយកិច្ចព្រមព្រៀង ការយកចិត្តទុកដាក់របស់ពិភពលោកបានប្រែប្រួល**" (Post-accords, the world's gaze shifted) របស់សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៦ ដែលក្នុងនោះអ្នកកាសែត Shaun Turton បានដកស្រង់ដោយខុសឆ្គងនូវខ្លឹមសារកិច្ចសន្ទនាជាមួយលោក Wiryono Sastrohandoyo តំណាងជាន់ខ្ពស់របស់រដ្ឋាភិបាលឥណ្ឌូនេស៊ី អញ្ជើញមកចូលរួមពិធីរំលឹកខួបទី ២៥ នៃសន្និសញ្ញាសន្តិភាពទីក្រុងប៉ារីស ដែលបានរៀបចំឡើងនៅទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ កាលពីថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦ ហើយបានសរសេរថា "**គាត់ (លោក Wiryono) បានរំលឹកឡើងវិញថា ហ៊ុន សែន ជាអ្នកធ្វើនយោបាយជាមួយនឹងអាវុធ** "(...he recalled Hun Sen was a man who plays politic with guns)។

នៅក្នុងការបំភ្លឺ ស្ថានទូតឥណ្ឌូនេស៊ីបានធ្វើការអះអាង ដូចខាងក្រោម៖

«- ព័ត៌មានដែលបានដកស្រង់មកនេះ មិនមានភាពត្រឹមត្រូវ ជាការដកស្រង់ដោយខុសឆ្គង ធ្វើឲ្យមានការយល់ច្រឡំ ដែលអាចធ្វើឲ្យសាធារណៈជនយល់ខុស ក៏ដូចជាអាចធ្វើឲ្យប៉ះពាល់ខ្លាំងដល់ទំនាក់ទំនងទ្វេភាគីដ៏ប្រសើររបស់យើង។

- មុនពេលចាកចេញពីភ្នំពេញ លោក Wiryono បានធ្វើការពន្យល់តាមរយៈស្ថានទូតឥណ្ឌូនេស៊ី ថា "ខ្ញុំមានភាពចាំបាច់ដើម្បីពន្យល់ចំពោះអត្ថបទរបស់សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ដែលក្នុងនោះ ខ្ញុំត្រូវបានគេដកស្រង់សំដីមិនត្រឹមត្រូវ។ បរិបទនៃការលើកឡើងនោះគឺនៅពេលដែលកម្ពុជាកំពុងស្ថិតនៅក្នុងសង្គ្រាមស៊ីវិល ដូច្នេះ គ្រប់ភាគីទាំងអស់ធ្វើនយោបាយជាមួយនឹងអាវុធ។ ជាគោលនយោបាយរបស់ឥណ្ឌូនេស៊ី

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ក្នុងការបញ្ចប់អវិភាពដោយការទប់ស្កាត់ផ្នែកការទូត។ ដូចនេះ មិនមានការពាក់ព័ន្ធអ្វីទាល់តែសោះដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន។

- អ្នកកាសែត Shaun Turton បានព្យាយាមជម្រុញលោក Wiryono ជាមួយនឹងសំណួរបង្កប់ដោយល្បិចកល ទោះបីជា លោក Wiryono បានបដិសេធមិនឆ្លើយសំណួររបស់គាត់ក៏ដោយ។ ឯកឧត្តមឯកអគ្គរដ្ឋទូត Wiryono បាននិយាយថាលោកមិនមានសិទ្ធ និងមុខតំណែងក្នុងការឆ្លើយសំណួរ និងផ្តល់ចំលើយអំពីស្ថានភាពនយោបាយនាពេលបច្ចុប្បន្ននៅកម្ពុជាទេ។ លោក Wiryono យល់ដឹងយ៉ាងច្បាស់ពីភាពចាំបាច់ក្នុងការថែរក្សាទំនាក់ទំនងទ្វេភាគីរវាងឥណ្ឌូនេស៊ី និងកម្ពុជា ដោយគោរពតាមគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងសាមគ្គីភាពរបស់អាស៊ាន។
- ស្ថានទូតឥណ្ឌូនេស៊ីបានស្នើសារព័ត៌មានភ្នំពេញប៉ុស្ដិ៍ឲ្យធ្វើការកែតំរូវជាចាំបាច់។»

ភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៦

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

Department of Information
and Documentation

# Press Release

The Ministry of Foreign Affairs and International Cooperation has received an official clarification from the Embassy of Indonesia in Phnom Penh concerning the article " **Post-accords, the world's gaze shifted**" of the Phnom Penh Post on 21 October 2016, in which Journalist Shaun Turton misquoted the conversation with Mr. Wiryono Sastrohandoyo, High Representative of Indonesia who attended the Commemoration of the 25th Anniversary of the Paris Peace Agreement held on 20 October 2016 at the Ministry of Foreign Affairs and International Cooperation, and wrote "....he recalled Hun Sen was a man who plays politic with guns."

In the clarification, the Embassy of Indonesia affirmed as follows:

«- The quoted news is inaccurate, misquoted, misleading, and could bring the wrong message to the public, as well as could potentially disturb our excellent bilateral relations.

- Before leaving Phnom Penh, Ambassador Wiryono explained through the Embassy and said " **I need to explain regarding Phnom Penh Post news item, in which I was reported in a misleading way. The context was the time when Cambodia was in civil war, so every faction was playing politics by the guns. It was Indonesia's policy to end the hostility by preventive diplomacy. Thus, there was even no reference at all to PM Hun Sen.**"

- Journalist Shaun Turton kept try to push Ambassador Wiryono with some trapped questions, even Ambassador Wiryono already refused to answer his questions. Ambassador Wiryono said that it is not in

Address : N° 3, **Samdech HUN Sen** Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 214 441, 216 122
Fax : (855) 23 216 144, 216 141
Email : mfaic@mfa.gov.kh

his capacity and domain to answer the questions and respond about the current political situation in Cambodia. He fully realized that we need to maintain the bilateral relations between Indonesia and Cambodia in the spirit of non-interference in domestic affairs and ASEAN solidarity.

- The Embassy has asked the Phnom Penh Post to make necessary revision.»

Phnom Penh, 28 October 2016